**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង**
**អំពើជួញដូរមនុស្ស**

លេខ...០៩៤/២១...រ.ប.ក

# របាយការណ៍ខែកញ្ញា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងទិសដៅខែតុលា ឆ្នាំ២០២១

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាននិងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក និងបន្ថែមដោយវិបត្តិនៃការរាតត្បាតដោយជំងឺកូវីដ១៩។

ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត បានបន្តទិសដៅការងារ ផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើបញ្ហាវិបត្តិកូវីដ១៩ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ និងត្រូវបន្ថែមភារកិច្ច ក្នុងការដោះស្រាយទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសអ្នកដែលវិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួនច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ ដើម្បីបង្ការទប់ស្កាត់ ការនាំចូលជំងឺកូវីដ១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈមក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់ការចាញ់បោកមេខ្យល់ ក្នុងការនាំពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថានភាពដែលមានការរឹតបន្តឹងពីប្រទេសគោលដៅ ដើម្បីការពារជំងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភពលោក ដែលធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាពជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"។
- ក្រសួងយុត្តិធម៌ ៖
  - រដ្ឋសភាបានអនុម័តច្បាប់ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA) (ត្រូវបានប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការណ៍ជាប្រញាប់ ដោយព្រះរាជក្រមលេខ នស/រកម ០៦២០/០២០ ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២០)។
  - បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

#### ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីបេបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

ខ.១.១. ការផ្សព្វផ្សាយតាមរយៈកម្មវិធីផ្សេងៗ

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖** អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សហការជាមួយអង្គការក្លែនអន្តរជាតិកម្ពុជា អង្គការសកម្មភាពដើម្បីកុមារ អង្គការឆាលហ្វាន់កម្ពុជា អង្គភាពការពារកុមារ និងដៃគូ បានរៀបចំ ពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ "ផែនការអនុវត្តគោលនយោបាយជាតិស្តីពី ប្រព័ន្ធកិច្ចការពារកុមារឆ្នាំ 2019-2029" តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច **ឯកឧត្តម វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មានអ្នកចូលរួមសរុបប្រមាណ ៣០០នាក់។

- **អគ្គលេខាធិការដ្ឋាន** គ.ជ.ប.ជ ដោយមានកិច្ចសហការបច្ចេកទេសពីក្រសួងសុខាភិបាល និងទទួលបានការគាំទ្រពីអង្គការយូនីសេហ្វ បានរៀបចំកម្មវិធីផ្សព្វផ្សាយ តាមប្រព័ន្ធអនឡាញ ស្ដីពី "ក្រមសីលធម៌ មន្ត្រីនៅមណ្ឌលចត្តាឡីស័ក និងសេវាគាំទ្រ" ក្រោមអធិបតីភាព លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ មានអ្នកចូលរួមសរុបប្រមាណ ៤០០នាក់។

### ខ.១.២. ការអប់រំដោយផ្ទាល់

នៅក្នុងខែកញ្ញា ឆ្នាំ២០២១នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្ដីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "**ភូមិ-ឃុំ មានសុវត្ថិភាព**" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន **៩.៦១៧**លើក មានអ្នកចូលរួមសរុបចំនួន **៤០៧.៥២១**នាក់ (ធៀបនឹងខែសីហា មានចំនួន **៥១២.៧០៦**នាក់ គឺមានការថយចុះចំនួន **១០៥.១៨៥**នាក់ ស្មើនឹង**២០,៥១%** ក្នុងនោះស្ត្រីចំនួន **២២៥.៦១៣**នាក់ ដូចមានតារាងលម្អិតខាងក្រោម៖

**តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ**

| ល.រ | ក្រសួង ស្ថាប័ន / រាជធានី-ខេត្ត | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្ត្រី |
| **ក្រសួង ស្ថាប័ន** | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ១៩ | ៣៩៣ | ១៩៦ | | | |
| | សរុប ក្រសួង ស្ថាប័ន | ១៩លើក | ៣៩៣នាក់ | ១៩៦នាក់ | | | |
| **រាជធានី-ខេត្ត** | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្ដាល | ៣៩៨ | ៨.៩៤៥ | ៤.៩៧៤ | ៤៦២ | ៣២.៤៦៧ | ១៦.៤០២ |
| ៣ | ខេត្តបាត់ដំបង | ៩០១ | ៣៩.៨៩៤ | ២១.៨៦១ | ៦១៧ | ១៧.៤៨៨ | ៩.៤៩០ |
| ៤ | ខេត្តពោធិ៍សាត់ | ៣៣៨ | ១៥.៦៩៩ | ៧.៦៧២ | ២៧ | ៨១៨ | ៣៤៨ |
| ៥ | ខេត្តសៀមរាប | ១៦ | ៣៤៥ | ១៧៨ | ១ | ២៥ | ១១ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.៣០៣ | ៣១.០៩៤ | ១៧.២០១ | ៧៧៣ | ១៥.២៩១ | ៨.៣៧០ |
| ៧ | ខេត្តកំពង់ចាម | ២.៣៨០ | ១៣៦.៣១០ | ៧៩.៨២៧ | ១.៤៦៩ | ៦៦.៩២២ | ៤០.៣០២ |
| ៨ | ខេត្តព្រះសីហនុ | | | | | | |
| ៩ | ខេត្តព្រះវិហារ | ៤ | ៩៥ | ៤៨ | | | |
| ១០ | ខេត្តស្វាយរៀង | | | | ២៥៦ | ៨.០៤៦ | ៤.៦៦៦ |
| ១១ | ខេត្តប៉ៃលិន | ៩៩ | ១.៣៥៩ | ៦៨៣ | ៣៤ | ១.០១១ | ៥១០ |
| ១២ | ខេត្តកោះកុង | | | | ១២ | ១៨៦ | ៩១ |
| ១៣ | ខេត្តកំពត | | | | | | |
| ១៤ | ខេត្តកំពង់ធំ | | | | | | |
| ១៥ | ខេត្តតាកែវ | | | | | | |
| ១៦ | ខេត្តក្រចេះ | ២៩ | ១.២៣១ | ៧៦១ | | | |
| ១៧ | ខេត្តកែប | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១៨ | ខេត្តកំពង់ស្ពឺ | ៤០១ | ១៩.៧៣១ | ១០.៩៣៥ | ៧៥ | ១០.១១២ | ១.០៤៩ |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ៣ | ៥៩ | ៣៨ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| សរុប រាជធានី-ខេត្ត | | ៥.៨៧២លើក | ២៥៤.៧៦២នាក់ | ១៤៤.១៧៨នាក់ | ៣.៧២៦លើក | ១៥២.៣៦៦នាក់ | ៨១.២៣៥នាក់ |
| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | | ចំនួនលើក ៩.៦១៧ លើក | | ចំនួនមនុស្ស ៤០៧.៥២១ នាក់ | | ចំនួនស្ត្រី ២២៥.៦១៣ នាក់ | |

**ខ.១.៣. ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

- ក្រុមជំនួយកិច្ចបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានផ្សព្វផ្សាយព័ត៌មាន និងច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមរយៈផេកហ្វេកប៊ុក មានអ្នកចូលមើលចំនួន ១៨.៥៦៨នាក់។
- ខេត្តសៀមរាបៈ មន្ទីរព័ត៌មាន បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ FM១០៣MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស ចំនួន ៣៧លើក (ផ្សាយផ្ទាល់ ១៦លើក និងចាក់ផ្សាយឡើងវិញ ២១លើក)។
  - អង្គការ A21 បានផ្សព្វផ្សាយតាមបណ្តាញសង្គមស្តីពី កិច្ចការពារកុមារ ចំនួន ០១លើក អ្នកចូលរួម ២៥៧នាក់ ស្រី១៤៧នាក់។
  - អង្គការ APLE កម្មវិធីបញ្ចូលរួមសហគមន៍ ឧស្សាហ៍កម្ម និងប្រព័ន្ធផ្សព្វផ្សាយ បានផ្សព្វផ្សាយសារ វីដេអូអប់រំកម្មវិធីលើកកម្ពស់ការយល់ដឹង វគ្គបណ្តុះបណ្តាល យុទ្ធនាការ និងសិក្ខាសាលា ដើម្បីបង្ការ ទប់ស្កាត់ការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ លើទំព័រហ្វេសប៊ុករបស់អង្គការAPLE។
- ខេត្តកំពង់ចាមៈ មន្ទីរពត៌មាន បានផ្សព្វផ្សាយតាមវិទ្យុជាតិភ្នំស្រីភ្នំប្រុស FM92.50MHz អំពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព រយៈពេល១ខែ។
- ខេត្តកំពង់ស្ពឺៈ បានចាក់ផ្សាយរឿងអប់រំខ្លីតាមវិទ្យុគិរីរម្យ ចំនួន២រឿង ១.បំបែកភាពស្ងៀមស្ងាត់ និងសេវាគាំទ្រពលករចំណាកស្រុក ២.បញ្ឈប់អំពើកេងប្រវ័ញ្ចការងារ និងការរើសអើងលើស្ត្រីពលករចំណាកស្រុក ចំនួន ៤៩លើក ឧបត្ថម្ភពីក្រសួងកិច្ចការនារី និងអង្គការ UN WOMEN។

**ខ.១.៤. ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ**

- ខេត្តកំពង់ចាមៈ បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ តាមវិទ្យុជាតិ ព្រមទាំងផ្សព្វផ្សាយតាមបណ្តាញសង្គមហ្វេសប៊ុក ចំនួយ០៤លើក ពាក់ព័ន្ធនឹង ការការពារទេសន្តរប្រវេសន៍ក្នុងបរិបទកូវីដ-១៩ និងការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស។

**ខ.២. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)**

- ខេត្តបន្ទាយមានជ័យៈ
  - អង្គការសាម៉ារីតាន់ភឺស ផ្តល់ការអប់រំ និងចែកប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព សរុបចំនួន ១.២២៤នាក់(ស្ត្រី ៤៧៦នាក់) កុមារ ៤៦នាក់ (កុមារី ៣៨នាក់)។
  - អង្គការ IOM ចែកសៀវភៅការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងនាមប័ណ្ណរបស់មជ្ឈមណ្ឌលផ្តល់ព័ត៌មានចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករវិលត្រឡប់ពីប្រទេសថៃ និងម៉ាឡេស៊ី ចំនួន ៨៣១នាក់(ស្រី ៣៣៦នាក់) កុមារ ០៧នាក់(កុមារី ០៧នាក់)។

## ២.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ២.៣.១. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពស្ថិតិពលរដ្ឋខ្មែរដែល៖
  - ចេញទៅក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់សរុបចំនួន ២១៥.១៧២ (ស្រី ៩៦.៤១២នាក់) អនីតិជន ៣.៧៨១នាក់ ក្នុងនោះ៖ ស្របច្បាប់ចំនួន ១៤២.៦៦៥នាក់ (ស្រី ៦៥.៥៨៣នាក់) អនីតិជន១.២៥៣ និងមិនស្របច្បាប់ចំនួន ៧២.២៧១នាក់ (ស្រី ៣០.៧៥១នាក់) អនីតិជន ២.៥២២នាក់។
  - វិលត្រឡប់មកកម្ពុជាវិញទាំងស្របច្បាប់ និងមិនស្របច្បាប់សរុបចំនួន ៧២.៨០៧នាក់ (ស្រី ៣០.៣៦៦នាក់) អនីតិជន៤៧០នាក់។
  - ដាច់ការទាក់ទង ២៣៦នាក់ ស្រី៧៨នាក់ អនីតិជន០៦នាក់។
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានធ្វើការបង្ការ ទប់ស្កាត់ពលរដ្ឋខ្មែរដែលធ្វើចំណាកស្រុកទៅប្រទេសថៃដោយខុសច្បាប់ចំនួន ០១លើក មនុស្សចំនួន ០៩នាក់ (ស្រី ០៣នាក់) អនីតិជន នាក់ និងបានធ្វើកិច្ចសន្យាអប់រំ ណែនាំ និងឱ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញ។
- កម្លាំងជំនាញវរៈនគរបាលការពារព្រំដែនគោក ខេត្តបាត់ដំបង វរៈសេនាតូចលេខ៨១៧, ៨១៩ និង ៣១០ បានចេញល្បាតតាមបន្ទាត់ព្រំដែនភូមិសាស្ត្ររបស់ខ្លួនបានចំនួន ១៤លើក បានទប់ស្កាត់ពលករខ្មែរឆ្លងដែនខុសច្បាប់ចំនួន ១៥៣នាក់(ស្រី ៥៤នាក់) អនីតិជន ៣០នាក់ រួចធ្វើការអប់រំ និងឱ្យវិលត្រឡប់ទៅលំនៅដ្ឋានវិញ។

### ២.៣.២. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ

- **អគ្គស្នងការដ្ឋាននគរបាលជាតិ**
- កម្លាំងជំនាញ នៃស្នងការដ្ឋាននគរបាលខេត្តក្រចេះ បន្ទាយមានជ័យ និងខេត្តរតនគិរី បានល្បាតឃ្លាំមើលគោលដៅសង្ស័យប្រព្រឹត្តបទល្មើស ចំនួន ០៧លើក។
- កម្លាំងជំនាញនៃស្នងការដ្ឋាននគរបាលខេត្តតាកែវ កែប បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ញាកម្ម ដល់ម្ចាស់អាជីវកម្ម ផ្ទះសំណាក់ ហាងម៉ាស្សា បានចំនួន ៩២គោលដៅ មនុស្សចូលរួម ២១៦នាក់ ស្រី១៤៨នាក់។
- **ខេត្តព្រះសីហនុ៖** រដ្ឋបាលខេត្តបានចេញសេចក្ដីជូនដំណឹង ស្ដីពី ការចាត់វិធានការរដ្ឋបាលនិងច្បាប់ចំពោះម្ចាស់ អគារ សណ្ឋាគារ និងកាស៊ីណូ ដែលប្រើប្រាស់ហត្ថពលករដោយបង្ខំ ដើម្បីដោះស្រាយ និងកាត់បន្ថយវិវាទការងារ ជាពិសេសទប់ស្កាត់ការបំពេញការងារដោយបង្ខំ ឬជាកាតព្វកិច្ចដែលអាចប្រឈមនឹងការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រោមរូបភាពរកការងារឱ្យធ្វើក្នុងទម្រង់កេងប្រវ័ញ្ចពលកម្ម។

### ២.៣.៣. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

- **ក្រសួងមហាផ្ទៃ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចំនួន ៧០គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។

## ខ.៤. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- **ខេត្តប៉ៃលិន៖** បានចុះអធិការកិច្ចដើម្បីទប់ស្កាត់ និងលុបបំបាត់នូវទម្រង់ជួញដូរដ៏ធ្ងន់ធ្ងរលើពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សែឡូ កាស៊ីណូ ឡូតដ្ឋ ភោជនីយដ្ឋាន និងអាហារដ្ឋាន ចំនួន ៨០កន្លែង ជាលទ្ធផលរកពុំឃើញមានជួញដូរកម្លាំងពលកម្មកុមារទេ។
- **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះទៅណែនាំផ្សព្វផ្សាយករណីការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារនៅតាមឡូតដ្ឋ ក្នុងនោះមានកុមារចំនួន ២០០នាក់ ហើយមន្ទីរបានឱ្យថៅកែធ្វើកិច្ចសន្យា។
- **ខេត្តក្រចេះ៖** មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចុះធ្វើអធិការកិច្ចលើការថែទាំជំនួសចំពោះ កុមារ នៅមណ្ឌលអង្គការដំណឹងល្អទាំងបួន និងភូមិកុមារកម្ពុជា SOS ខេត្តក្រចេះ ចំនួន ០២លើក ជាលទ្ធផលឃើញថា ការថែទាំ និងការឧបត្ថម្ភដល់កុមារ បានដំណើរការល្អប្រសើរ។
- **ខេត្តព្រះសីហនុ៖** បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញដែលបានដាក់ចំនួន ១.១៣៣នាក់ (ម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍) ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។

# គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

## គ.១. ការអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ២៧ករណី(ធៀបនឹងខែ សីហា មានចំនួន ២៦ករណី កើនឡើងចំនួន ០១ករណី) ស្មើនឹង៣,៨៤% ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ៤១នាក់ ស្រី០១នាក់ ក្នុងនោះជនសង្ស័យជាអនីតិជន ០២នាក់ និងជនបរទេស០២នាក់(អាមេរិក ០១នាក់ បារាំង០១នាក់)។

សង្គ្រោះជនរងគ្រោះ ចំនួន ១១៦នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ២៧នាក់ អាយុ១៥-១៧ឆ្នាំ ០៩នាក់ និងអាយុពី១៨ឆ្នាំឡើង ៨០នាក់ ប្រគល់ឱ្យគ្រួសារ១១៦នាក់) ក្នុងនោះចែកជា៖

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ១៤ករណី/១៧ករណី (ថយ ០៣ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ២៧នាក់ ស្រី០១នាក់ និងជនបរទេសសញ្ជាតិអាមេរិក ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៩៧នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ០៨នាក់ អាយុ១៥-១៧ឆ្នាំ ០៩នាក់ និងអាយុ១៨ឆ្នាំឡើង ៨០នាក់ (ប្រគល់ឱ្យគ្រួសារ ៩៧នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ១១ | ៨៨ | ២៣ | |
| -អំពើលក់ដូរមនុស្ស | ០១ | ០៤ | ០២ | |
| -ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០១ | ០២ | ០១ | |
| -ការទិញពេស្យាចារកុមារ | ០១ | ០៣ | ០១ | អាមេរិក១ |
| *សរុប* | *១៤ ករណី* | *៩៧ នាក់* | *២៧ នាក់* | *០១ នាក់* |

### ២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ១៣ករណី/០៩ករណី (កើនចំនួន ០៤ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ១៤នាក់ ជនសង្ស័យជាអនីតិជន ០២នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១៩នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ១៩នាក់ (ប្រគល់ឱ្យគ្រួសារ ១៩នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|---|
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ១១ | ១៧ | ១២ (អនីតិជន២) | បារាំង១ |
| -អំពើអាសប្រថាំងនឹងអនិតិជនអាយុក្រោម១៥ឆ្នាំ | ០២ | ០២ | ០២ | |
| *សរុប* | *១៣ ករណី* | *១៩ នាក់* | *១៤ នាក់ (អនីតិជន២)* | *០១ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និង ផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល នឹងសម្ភាសពលករបញ្ជូនត្រឡប់

- **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានា សរុបចំនួន ៤៩នាក់(ស្ត្រី ៤០នាក់ កុមារ០១នាក់ កុមារី០៥នាក់) មកពីប្រទេសចិន៤២នាក់ ថៃ០១នាក់ និងម៉ាឡេស៊ី០៦នាក់ ជាករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម ០៣នាក់ ជួញដូរកម្លាំងពលកម្ម០១នាក់ អាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ ៤២នាក់ និងករណីងាយរងគ្រោះ ០៣នាក់ បានធ្វើការសម្ភាសន៍កំណត់អត្តសញ្ញាណ រួចបញ្ជូនទៅទទួលសេវានៅអង្គការដៃគូ។

- **អគ្គស្នងការដ្ឋាននគរបាលជាតិៈ**

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានទទួល និងសម្ភាសន៍ជនរងគ្រោះដែលបានវិលត្រឡប់មកពីប្រទេសចិនតាមរយៈអនឡាញ ចំនួន ២៣នាក់(ស្រី) ជាលទ្ធផល ជនរងគ្រោះទៅតាមរយៈមេខ្យល់មិនស្គាល់អត្តសញ្ញាណទាំងអស់។ និងបានប្រមូលព័ត៌មានពីសុខទុក្ខនារីខ្មែរដែលរៀបការទៅរស់នៅក្រៅប្រទេស(កូរ៉េខាងត្បូង)តាមរយៈទូរស័ព្ទ ចំនួន០៦នាក់ មានសេចក្តីសុខឧម្មតា។

- **ខេត្តបន្ទាយមានជ័យៈ** ក្រុមការងារបានទទួល និងសម្ភាសន៍ជនទេសន្តប្រវេសន៍(ពលរដ្ឋខ្មែរ) ដែលអាជ្ញាធរថៃបញ្ជូនតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ប្រចាំខែកញ្ញា ឆ្នាំ២០២១ សរុបចំនួន ៨.៧២០នាក់(ស្ត្រី ៣.៥៥៣នាក់) អនីតិជន ៧៧២នាក់។

### ឃ.២. ការស្តារនីតិសម្បទា

- ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស បានបញ្ជូនទៅស្តារនីតិសម្បទា នៅមជ្ឈមណ្ឌលរបស់អង្គការដៃគូ សរុបចំនួន ១.៤៧៧នាក់(ស្រី១០២នាក់ កុមារ៧៤១នាក់ កុមារី៦២៣នាក់) ក្នុងនោះករណីងាយរគ្រោះចំនួន ១.១០៣នាក់។

### ឃ.៣. ការធ្វើសមាហរណកម្មជនរងគ្រោះ និងជនងាយរងគ្រោះ

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត បានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ បានធ្វើសមាហរណកម្មជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ឱ្យទៅសហគមន៍វិញ សរុបចំនួន ៣៥នាក់(ស្ត្រី២៩នាក់ កុមារី០៤នាក់) ជាករណីអាពាហ៍ពិពាហ៍ផ្ទុយពីធន្ទៈ/បង្ខំ ៣៣នាក់ កេងប្រវ័ញ្ចកម្លាំងពលកម្ម០២នាក់។

## III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

### ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

#### ក.១. ការងារបណ្តុះបណ្តាល

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- បើកវគ្គបណ្តុះបណ្តាល ស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្តល់សេវាសមស្រប ដល់សិក្ខាកាមជា មន្ត្រីនៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- បើកវគ្គបណ្តុះបណ្តាល តាមប្រព័ន្ធអនឡាញ ស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្តល់សេវាសមស្រប ដល់សិក្ខាកាមជា ស្នងការរងនគរបាលខេត្ត មេបញ្ជាការរងកងរាជអាវុធហត្ថខេត្ត តំណាងពីមន្ទីរសង្គមកិច្ច កិច្ចការនារី មន្ទីរការងារ មន្ត្រីជំនាញ និងអង្គការដៃគូរពាក់ព័ន្ធនានា នៅខេត្តសៀមរាប។ | ០១<br>០១ | ៤៧<br>១៨៥ | ០៧<br>- |
| **ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** បានរៀបចំវគ្គបណ្តុះបណ្តាលលើគោនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះ និងគោលការណ៍ណែនាំស្តីពី បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅស្រុកកំពង់ពោធិ៍ ខេត្តស្វាយរៀង។ | ០២ | ៧៨ | ២៦ |
| **ខេត្តកំពង់ឆ្នាំង៖** មន្ទីរកិច្ចការនារី បានបើកវគ្គបណ្តុះបណ្តាលស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព អំពើជួញដូរមនុស្ស និងផ្សព្វផ្សាយវិធានការការទប់ស្កាត់ជំងឺកូវីដ-១៩។ | ០២ | ៥៩ | ៣០ |
| **ខេត្តត្បូងឃ្មុំ៖**<br>- គ.ខ.ប.ជ ខេត្ត សហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី បើកវគ្គបណ្តុះបណ្តាលស្តីពី ការគ្រប់គ្រង និងការបញ្ជូនករណីរងគ្រោះដោយអំពើជួញដូរមនុស្ស ដល់ក្រុមជំនាញទាំង៦ ក្រុង-ស្រុកទាំង៧ និងលេខាធិការដ្ឋាន គ.ខ.ប.ជ តាមប្រព័ន្ធអនឡាញ។<br>- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយអង្គការមូលនិធិហាការអន្តរជាតិ បើកវគ្គបណ្តុះបណ្តាលស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់អាជ្ញាធរមូលដ្ឋានឃុំតំបែរ។ | ០១<br>០១ | ២៥<br>២០ | <br>០៥ |
| **ខេត្តកំពង់ចាម៖** រដ្ឋបាលស្រុកចំការលើ បានបើវគ្គបណ្តុះបណ្តាលស្តីពី ការលើកកម្ពស់ និងការពារសិទ្ធិសម្រាប់ជនចំណាកស្រុកកម្ពុជា ដែលមានជំនាញទាបទៅធ្វើការនៅប្រទេសថៃ និងវគ្គបណ្តុះបណ្តាលស្តីពី ការចំណាកស្រុកដោយសុវត្ថិភាព ។ | ០៣ | ៥១ | ៤០ |
| **ខេត្តបាត់ដំបង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បើកវគ្គបណ្តុះបណ្តាលស្តីពី ទេសន្តរប្រវេសន៍ និងការជ្រើសរើសពលករប្រកបដោយក្រមសីលធម៌ ដល់អាជ្ញាធរមូលដ្ឋាន និងទីភ្នាក់ងារជ្រើសរើសឯកជន តាមប្រព័ន្ធអនឡាញ។ | ០១ | ៤៤ | |
| **ខេត្តសៀមរាប៖** លេខាធិការដ្ឋានគ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត សហការជាមួយអង្គការ IOM បើកវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ ស្តីពីការគ្រប់គ្រងទិន្នន័យពលករចំណាកស្រុកក្រៅប្រទេស និងការរៀបចំបាយការណ៍ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់ក្រុមការងារថ្នាក់ក្រុង ស្រុក។ | ០១ | ៤៧ | ២១ |

| | | | |
|---|---|---|---|
| **អង្គការបណ្ដាញទូរស័ព្ទជំនួយកុមារកម្ពុជា** បើកវគ្គបណ្តុះបណ្តាល តាមប្រព័ន្ធអនឡាញ ស្តីពី ការពិគ្រោះយោបល់តាមបែបដោះស្រាយបញ្ហា ជាលើកទី៤។ វគ្គបណ្តុះបណ្តាលនេះមានគោលបំណង ផ្តល់ចំណេះដឹង និងជំនាញវិជ្ជាជីវៈច្បាស់លាស់ ដើម្បីផ្តល់សេវាគាំទ្រផ្លូវចិត្ត និងផ្តល់សេវាចាំបាច់ ដើម្បីឆ្លើយតបសម្រាប់ស្ត្រីពលករ ចំណាកស្រុក ដើម្បីរកការងារធ្វើនៅប្រទេសគោលដៅ និងប្រទេសកំណើតដែល ជួបប្រទះបញ្ហាអំពើហិង្សាលើស្ត្រី អំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម។ល។ | ០១ | ២៦ | |
| **ខេត្តស្វាយរៀង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយក្រុមហ៊ុនចំនួន ០៨ បានបើកវគ្គបណ្តុះបណ្តាល ដោយបានបញ្ជ្រាបការយល់ដឹងអំពីចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទស្តីពី បំនិនជីវិត ច្បាប់ស្តីពីការងារ សុខភាព និង សុវត្ថិភាពការងារ និងការជួយសង្គ្រោះបឋម ដែលមានសិក្ខាកាមចូលរួមសរុបចំនួន១៤៧នាក់ ស្រី ៨៨ នាក់ ។ | ០១ | ១៤៧ | ៨៨ |
| សរុប | **១៥វគ្គ** | **៧២៩នាក់** | **២១៧នាក់** |

## ក.២. សិក្ខាសាលា

| សកម្មភាពរៀបចំសិក្ខាសាលា | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការជាមួយ អង្គការការីតាសស្វីស** បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើកទី៣ ស្តីពី ការពង្រឹងសេវាសម្របសម្រួល ដើម្បីសុវត្ថិភាពពលករ និងសហគមន៍ នៅខេត្តបាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ និងខេត្តសៀមរាប ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។ | ០៣ | ១០៩ | ៣៥ |
| **ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** សហការជាមួយ អង្គការអន្តរជាតិខាងការងារ អង្គការទេសន្តរប្រវេសន៍អន្តរជាតិ និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ បើកសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ តាមប្រព័ន្ធអនឡាញ ស្តីពី កម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍ ដែលដឹកនាំដោយ ឯកឧត្តម **ហ៊ូ វ៉ុន្នី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ | ០១ | ៦០ | - |
| **អង្គការ ASEAN-ACT** បើកសិក្ខាសាលាពិគ្រោះយោបល់ តាមប្រព័ន្ធអនឡាញ ស្តីពី "ការពិគ្រោះយោបល់ វាយតម្លៃសមត្ថភាព និងអភិវឌ្ឍន៍សមត្ថភាព" ជាមួយដៃគូវិស័យយុត្តិធម៌ និងវិស័យសង្គមកិច្ច ដែលជាស្ថាប័នកំពុងអភិវឌ្ឍន៍យុទ្ធសាស្ត្រសំខាន់ៗ ក្នុងការឆ្លើយតបទៅនឹងការជួញដូរមនុស្ស និងការអនុវត្តអនុសញ្ញាអាស៊ានស្តីពី ការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារនៅកម្ពុជា។ | ០១ | ៣៦ | - |
| **ខេត្តសៀមរាប៖** ដោយបានសហការជាមួយក្រសួងយុត្តិធម៌ និងអង្គការ APLE រៀបចំសិក្ខាសាលាតាមប្រព័ន្ធអនឡាញស្តីពី ការអនុវត្តបែបកុមារមេត្រី ដើម្បីការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមាររងគ្រោះ នៃអំពើរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទ ក្នុងនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ និងការអនុវត្តសំណងរដ្ឋប្បវេណីតាមនីតិវិធីតុលាការ។ | ០១ | ១០៥ | |
| **ខេត្តស្វាយរៀង លេខាធិការដ្ឋាន គ.ខ.ប.ជ៖**<br>- សហការជាមួយ អង្គការអាយស៊ីស៊ី រៀបចំសិក្ខាសាលាផ្សព្វផ្សាយ អំពីច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដល់គណៈកម្មាការពិគ្រោះយោបល់ស្ត្រី និងកុមារ តាមប្រព័ន្ធអនឡាញ ក្នុងគោលបំណងដើម្បីផ្តល់ការយល់ដឹងអំពីកុមារទំនាស់នឹងច្បាប់ កត្តាដែលនាំឲ្យកុមារទំនាស់នឹងច្បាប់ និងប្រព័ន្ធយុត្តិធម៌ព្រហ្ម។ | ០១ | ២៣ | |

| | | | |
|---|---|---|---|
| - សហការជាមួយអង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) រៀបចំវគ្គសិក្ខាសាលាផ្សព្វផ្សាយច្បាប់ "ស្តីពីការប្រឆាំងអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ក្នុងបរិបទកូវីដ ១៩ តាមប្រព័ន្ធZoom ក្រោមអធិបតីភាពលោកជំទាវ ឯក សុវណ្ណភារៈ អភិបាលរងខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍គ.ខ.ប.ជ។ | ០១ | ១៦០ | |
| សរុប | ០៨វគ្គ | ៤៩៣នាក់ | ៣៥នាក់ |

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. ក្នុងប្រជុំក្នុងប្រទេស និងក្រៅប្រទេស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

  - លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញដឹកនាំះ

  - ប្រជុំពិភាក្សារៀបចំមេរៀនសម្រាប់វគ្គបណ្តុះបណ្តាល ដល់មន្ត្រីពាក់ព័ន្ធនៅតាមគោលដៅ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្តល់សេវាសមស្រប ចំនួន០៥លើក នៅសាលប្រជុំគ.ជ.ប.ជ។
  - កិច្ចប្រជុំពង្រឹងសមត្ថភាពគ្រូបង្គោលត្រៀម សម្រាប់វគ្គបណ្តុះបណ្តាលមេរៀន ការកំណត់អត្តសញ្ញាណជនរងគ្រោះដល់មន្ត្រីពាក់ព័ន្ធនៅតាមគោលដៅដែលពលករវិលត្រលប់ នៅសាលប្រជុំគ.ជ.ប.ជ។
  - កិច្ចប្រជុំវាយតម្លៃក្រុមគ្រូបង្គោល សម្រាប់វគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្តល់សេវាសមស្រប នៅសាលប្រជុំគ.ជ.ប.ជ។

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាះ

  - បានសហការជាមួយអង្គការទេសន្តរប្រវេសន៍អន្តរជាតិ (IOM) រៀបចំកិច្ចប្រជុំត្រៀមប្រជុំជាមួយភាគី ថៃស្តីពី ការពិនិត្យ ពិភាក្សាលើទម្រង់គ្រប់គ្រងករណី និងឧបសម្ព័ន្ធក្នុងការអនុវត្តនីតិវិធីប្រតិបត្តិបទដ្ឋាន(SOPs) រវាងព្រះរាជាណាចក្រកម្ពុជា-ថៃ តាមប្រព័ន្ធអនឡាញ។
  - ក្រុមការងារបច្ចេកទេស បានរៀបចំកិច្ចប្រជុំចង្អៀត ដើម្បីរៀបចំនីតិវិធីការអនុវត្តគោលការណ៍ណែនាំនៃដំណើរការមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស តាមប្រព័ន្ធអនឡាញ ដែលមានការគាំទ្រពីអង្គការវតនះអ៊ិនធើណេសិនណល។

### ខ.២. ជំនួបពិភាក្សាការងារ

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានជួបពិភាក្សាការងារ ជាមួយតំណាងអង្គការចាប់ដៃ ស្តីពី កិច្ចសហប្រតិបត្តិការការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីត្រៀមរៀបចំសិក្ខាសាលាពិគ្រោះយោបល់ក្នុងការផ្តល់សេវាជួយជនរងគ្រោះពីអំពើជួញដូរមនុស្ស។

## គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ ៨៣លើក មានអ្នកចូលរួមសរុប ១.៥០៩នាក់ (ស្រី១៨៧នាក់) ក្នុងនោះមាន គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ៣៤លើក ក្រសួងសង្គមកិច្ចអតីតយុទ្ធ និងយុវនីតិសម្បទា ចំនួន ០៧លើក និងលេខាធិការដ្ឋានរាជធានី ខេត្ត ចំនួន ៤២លើក។(ឧបសម្ព័ន្ធ១)

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជាគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជា៖

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។

- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

# V. ទិសដៅខែតុលា ឆ្នាំ២០២១

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃសុក្រ ៥ កើត ខែកត្តិក ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០២១

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ-ប៊ុនអេង

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**

- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**-ដើម្បីជូនជ្រាប-**

- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធទី១

### តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៨៣លើក) មនុស្សចំនួន ១.៥០៩នាក់ (ស្រី ១៣៦នាក់)

| ស្ថាប័នសម្របសម្រួល | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | ▪ លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>- ពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ផែនការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ ដែលរៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សហការជាមួយអង្គការភ្លែនអន្តរជាតិកម្ពុជា អង្គការសកម្មភាពដើម្បីកុមារ អង្គការឆោលហ្វាន់កម្ពុជា អង្គភាពការពារកុមារ និងដៃគូ ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ តាមប្រព័ន្ធអនឡាញ។<br>- ជាអធិបតីភាពថ្លែងសុន្ទរកថាបើកវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅខេត្តសៀមរាប តាមប្រព័ន្ធអនឡាញ ដែលមានសិក្ខាកាមចូលរួមជាមន្ត្រីជំនាញពាក់ព័ន្ធប្រមាណ **១៨៨**នាក់។<br>- និងបានដឹកនាំក្រុមការងារ នាំយកសម្ភារៈ បរិក្ខាអនាម័យមួយចំនួន មានដូចជាអាកុល ០៣កាន ម៉ាស់ ០៦កេសធំ និងដបបាញ់អាកុល ២០០ដប ជូនដល់នគរបាលនៃការិយាល័យអន្តោប្រវេសន៍ ប្រចាំច្រកទ្វារអន្តរជាតិប៉ោយប៉ែត ថ្នាក់ដឹកនាំ ហើយបានបន្តដំណើរទស្សនៈកិច្ចទៅកាន់ ការិយាល័យច្រកទ្វារអន្តោប្រវេសន៍ថ្មីដែលទើបសាងសង់រួច(ប៉ោយប៉ែត) ក៏បន្តដំណើរទស្សនកិច្ចទៅកាន់ច្រកទ្វារស្ទឹងបត់ ដែលរាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ កម្ពុជា ថៃ បានសម្រេចបើកឱ្យដំណើរការ សម្រាប់ជួយសម្រួលលំហូរពាណិជ្ជកម្មនានា រវាងប្រទេសទាំងពីរកាន់តែមានភាពងាយស្រួល និងបានឆាប់រហ័សជាងមុន។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៊ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖<br>- កិច្ចប្រជុំបន្តពិភាក្សាការរៀបចំមេរៀនសម្រាប់វគ្គបណ្តុះបណ្តាលដល់មន្ត្រីពាក់ព័ន្ធនៅតាមគោលដៅ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។<br>- កិច្ចប្រជុំពង្រឹងសមត្ថភាពគ្រូបង្គោលត្រៀមសម្រាប់វគ្គបណ្តុះបណ្តាលមេរៀន ការកំណត់អត្តសញ្ញាណជនរងគ្រោះ ដល់មន្ត្រីពាក់ព័ន្ធនៅតាមគោលដៅដែលពលករវិលត្រលប់ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។<br>- សិក្ខាសាលាពិគ្រោះយោបល់លើកទី៣ ស្តីពី ការពង្រឹងសេវាសម្របសម្រួលដើម្បីសុវត្ថិភាពពលករ និងសហគមន៍ ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅខេត្តសៀមរាប។ |

- ប្រជុំតាមអនឡាញ សម្រាប់ប្រជុំទ្វេភាគីថ្នាក់បច្ចេកទេសលើកទីពីរ កម្ពុជា ថៃ លើឧបសម្ព័ន្ធ ស្តីពី បែបបទ និងនីតិវិធីនៃដំណើរមាតុភូមិនិវត្តន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម ញឹក វណ្ណា៉ រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅបន្ទប់សាលប្រជុំគ.ជ.ប.ជ ចំនួន០២លើក។
- លោកជំទាវ អគ្គលេខាធិការគ ជ.ប.ជ.និងក្រុមការងារបច្ចេកទេសសុខភាពជនទេសន្តរប្រវេសន៍ថ្នាក់ជាតិ នៃក្រសួងសុខាភិបាល តំណាងអង្គការអន្តរជាតិIOM តំណាងADB បានអញ្ជើញចុះបំពេញទស្សនកិច្ចរួមគ្នា នៅតាមបន្ទាត់ព្រំដែនប្រទេសកម្ពុជា ថៃ(បន្ទាយមានជ័យ ប៉ៃលិន បាត់ដំបង) លើការប៉ាន់ប្រមាណតម្រូវការសេវាសុខាភិបាលជនទេសន្តរប្រវេសន៍កម្ពុជា ដែលបានត្រលប់មក។
- កិច្ចប្រជុំវាយតម្លៃក្រុមគ្រូបង្គោល សម្រាប់វគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។
- បើកវគ្គបណ្តុះបណ្តាល ស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ក្នុងគោលបំណង ដើម្បីឱ្យអ្នកមានភារកិច្ច កំណត់អត្តសញ្ញាណជនរងគ្រោះ យល់បានច្បាស់ ពីនីតិវិធី និងអាចប្រើប្រាស់ បែបបទដែលពាក់ព័ន្ធ ក្នុងដំណើរការនៃការកំណត់អត្តសញ្ញាណជនរងគ្រោះ យល់ដឹងអំពីច្បាប់ និងអាចសន្និដ្ឋានជាបឋម ដោយភាពប្រាកដប្រជា ដើម្បីទទួលបានលទ្ធផល និងព័ត៌មានត្រលប់ស្តីពី ការប្រើប្រាស់បទដ្ឋាននានា ភាពប្រឈម និង ចំនុចខ្វះខាតនៃការណែនាំក្នុងការអនុវត្ត ដើម្បីកែលម្អ ជាមួយរដ្ឋបាល ខេត្តសៀមរាប តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។
- លោកជំទាវ អគ្គលេខាធិការគ.ជ.ប.ជ អមដំណើរដោយ លោកជំទាវ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង បានសហការរៀបចំ និងចូលរួមកម្មវិធីផ្សព្វផ្សាយស្តីពី ក្រមសីលធម៌មន្ត្រី នៅមណ្ឌលចត្តាឡីស័ក និងសេវាគាំទ្រ តាមប្រព័ន្ធអនឡាញ ដោយមានកិច្ចសហការបច្ចេកទេសពីក្រសួងសុខាភិបាល និងទទួលបានការគាំទ្រពីអង្គការយូនីសេហ្វ កម្មវិធីផ្សព្វផ្សាយនេះមានការចូលរួមពីតំណាង ក្រសួងមហាផ្ទៃ ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច ព្រមទាំងសមាសភាពពាក់ព័ន្ធ ពីបណ្តាខេត្តគោលដៅ មានចំនួន៨ខេត្តចូលរួមគឺ ខេត្តស្ទឹងត្រែង ខេត្តរតនគីរី ខេត្តមណ្ឌលគីរី ខេត្តក្រចេះ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តស្វាយរៀង ខេត្តព្រៃវែង ដែលមានអ្នកចូលរួមសរុបប្រមាណ ៤៧៨នាក់។
- ពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការ ផែនការអនុវត្តគោលនយោបាយជាតិ ស្តីពីប្រព័ន្ធកិច្ចការពារកុមារតាមប្រព័ន្ធអនឡាញ ឆ្នាំ២០១៩-២០២៩ ដែលរៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សហការជាមួយនឹងអង្គការភ្លែនអន្តរជាតិកម្ពុជា អង្គការសកម្មភាពដើម្បីកុមារ អង្គការឆាលហ្វាន់កម្ពុជា អង្គភាពការពារកុមារ និងដៃគូ ក្រោមអធិបតីភាព លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ តាមប្រព័ន្ធអនឡាញ។
- កិច្ចពិភាក្សាការងារជាមួយលោកស្រី Kristin Parco ប្រធានអង្គការ IOM ស្តីពី"ការងារទេសន្តប្រវេសន៍" តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។

- **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**
  - លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១៤ច្បាប់ លិខិតចូល ១០ច្បាប់។
  - លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ២២ច្បាប់ លិខិតចូល ១១ច្បាប់។
  - រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។
  - បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែកញ្ញា ឆ្នាំ២០២១ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
  - បូកសរុបរបាយការណ៍ខែកញ្ញា ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
  - ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។
  - រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។
  - ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវិតី ២៦សកម្មភាព។
  - ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។
  - ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាន នានា រក្សាទុកក្នុងបណ្ណាល័យ Wiki ncct Convert ជា PDF បានចំនួន១៣៥ច្បាប់។
- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**
  - ឯកឧត្តមឧត្តមសេនីយ៍ទោ **កែវ សុវណ្ណារ៉ា** អគ្គលេខាធិការរង បានចូលរួម៖
    - ពិភាក្សានៅក្នុងសិក្ខាសាលាពិគ្រោះយោបល់តាមរយៈប្រព័ន្ធអនឡាញ ស្តីពីការពិគ្រោះយោបល់វាយតម្លៃសមត្ថភាព និងអភិវឌ្ឍន៍សមត្ថភាព ដែលរៀបចំដោយកម្មវិធី ASEAN-ACT ក្រោមប្រធានបទដែលជាវិស័យអាទិភាពចំនួន០២ ជាមួយដៃគូវិស័យយុត្តិធម៌ និងសង្គមកិច្ច ជាមួយរដ្ឋជាសមាជិកអាស៊ានដទៃទៀត ក្នុងកិច្ចការពារពលករចំណាកស្រុក ដោយផ្តោតសំខាន់ទៅលើការពិនិត្យមើលយុទ្ធសាស្ត្រ និងអភិក្រមនៃកម្មវិធី ASEAN-ACT ដើម្បីយល់ដឹងរួមអំពីចំណុចខ្លាំងនៃស្ថាប័នដៃគូវិស័យយុត្តិធម៌ និងសង្គមកិច្ច និងអនាគតអាទិភាពអភិវឌ្ឍន៍សមត្ថភាពស្ថាប័ន និងទិន្នន័យដើមគ្រា និងកត្តាជោគជ័យសម្រាប់វាយតម្លៃវឌ្ឍនភាព។
    - កិច្ចប្រជុំពង្រឹងសមត្ថភាពគ្រូបង្គោលត្រៀម  សម្រាប់វគ្គបណ្តុះបណ្តាលមេរៀនការកំណត់អត្តសញ្ញាណជនរងគ្រោះ  ដល់មន្ត្រីពាក់ព័ន្ធនៅតាមគោលដៅដែលពលករវិលត្រលប់ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។
    - កិច្ចប្រជុំវាយតម្លៃលើក្រុមគ្រូបង្គោលសម្រាប់វគ្គបណ្តុះបណ្តាលស្តីពី  ការកំណត់អត្តសញ្ញាណជនរងគ្រោះ  ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។
    - ពិធីបើកវគ្គបណ្តុះបណ្តាលតាមប្រព័ន្ធអនឡាញ  ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស  ដើម្បីផ្តល់សេវាសមស្រប  នៅខេត្តសៀមរាប ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។

- លោកឧត្តមសេនីយ៍ទោ រ៉ែន សុភ័ក្រ្តវឌ្ឍនា ប្រធានក្រុម បានចូលរួមប្រជុំរៀបចំមេរៀនសម្រាប់វគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមការដឹកនាំសម្របសម្រួលដោយ លោកជំទាវ អគ្គលេខាធិការគ.ជ.ប.ជ។
- ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានបូកសរុបលទ្ធផលសកម្មភាពការងារប្រចាំខែ របស់ក្រុមការងារបង្ការ ទប់ស្កាត់ ដោយធ្វើការបូកសរុបលទ្ធផលពីបណ្តារាជធានី-ខេត្ត និងក្រសួង ស្ថាប័នពាក់ព័ន្ធ។
- បានបន្តផ្សព្វផ្សាយឯកសារលិខិតបទដ្ឋាននានាពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស តាមរយៈផេកផ្លូវការរបស់ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ក៏ដូចជាសកម្មភាពនានារបស់ថ្នាក់ដឹកនាំ។

▪ **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**

- ឯកឧត្តម អគ្គលេខាធិការរង បានចូលរួម៖
  - កិច្ចប្រជុំថ្នាក់បច្ចេកទេស(កម្រិតជំនាញ) ដើម្បីត្រៀមរៀបចំកិច្ចប្រជុំជាមួយភាគីថៃ ស្តីពីការពិនិត្យ ពិភាក្សាលើទម្រង់គ្រប់គ្រងករណី និងឧបសម្ព័ន្ធ ក្នុងការអនុវត្តនីតិវិធីប្រតិបត្តិបទដ្ឋាន ការគ្រប់គ្រងករណី នៃការធ្វើមាតុភូមិនិវត្តន៍ និងសមាហរណកម្មជនរងគ្រោះ(SOP) រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ តាមប្រព័ន្ធអនឡាញក្រោមអធិបតីភាព ឯកឧត្តម **ញឹក វណ្ណារ៉ា** រដ្ឋលេខាធិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
  - ជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដល់សិក្ខាកាមមកពី មន្ទីរ អង្គភាព ចំណុះរដ្ឋបាលខេត្តសៀមរាប តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។

▪ **ក្រុមជំនួយកិច្ចយុត្តិធម៌**

- បានចូលរួមប្រជុំបង្កើតស្លាយមេរៀនតាមការចាត់តាំងរបស់ លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ដើម្បីត្រៀមខ្លួនធ្វើបទបង្ហាញសាកល្បងជាមួយមន្ត្រី អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ក្នុងគោលបំណងស្ទាបស្ទង់សមត្ថភាពមុននឹងក្លាយជាគ្រូបង្គោលសម្រាប់បណ្តុះបណ្តាលថ្នាក់ក្រោមជាតិនាពេលខាងមុខ។
- ប្រជុំទទួលយកការបណ្តុះបណ្តាលបន្ថែមពី លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ អំពីរបៀប និងវិធីសាស្ត្រ ក្នុងការបង្រៀន និងការឆ្លើយតបសំណួររបស់សិក្ខាកាម នៅពេលបង្រៀន ដើម្បីត្រៀមបង្រៀនសាកល្បងមន្ត្រីក្នុងអង្គភាព។
- ប្រជុំក្នុងក្រុមគ្រូបង្គោល ដើម្បីបែងចែកស្លាយមេរៀន និងសៀវភៅបច្ចេកទេសសម្រាប់បង្រៀន ដែលលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ទើបបានកែតម្រូវ និងធ្វើបច្ចុប្បន្នភាពថ្មី ដើម្បីឱ្យគ្រូបង្គោលម្នាក់ៗបានដឹងពីតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន និងត្រៀមខ្លួនសម្រាប់បើកវគ្គបណ្តុះបណ្តាលនៅខេត្តសៀមរាប ជាការសាកល្បងបឋម ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ និងលោកជំទាវ អគ្គលេខាធិការគ.ជ.ប.ជ។
- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដល់ថ្នាក់ដឹកនាំ និងមន្ត្រីគ.ខ.ប.ជ ខេត្តសៀមរាប។

- បានចូលរួមកិច្ចពិភាក្សារវាង លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ និងលោកស្រី Kristin Parco ប្រធានអង្គការ IOM ស្តីពី«ការងារទេសន្តប្រវេសន៍» តាមប្រព័ន្ធអនឡាញ ក្នុងនាមជាប្រទេសទទួលជ័យលាភី ក្នុងការការពារពលករទេសន្តរប្រវេសន៍កម្ពុជាឱ្យមានសុវត្ថិភាព រៀបរយ និងស្របច្បាប់។

▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**

- លោកជំទាវ ឧត្តមសេនីយ៍ទោ រ៉ែន **សិរីលក្ខិណា** អគ្គលេខាធិការរង បានអញ្ជើញចូលរួម៖
  - ◦ សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី "កម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍" តាមប្រព័ន្ធអនឡាញ ជាមួយអង្គការ ILO ដែលរៀបចំសហការដោយក្រសួងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។
  - ◦ រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើកទី៣ ស្តីពីការពង្រឹង សេវាសម្របសម្រួលដើម្បីសុវត្ថិភាពពលករ និងសហគមន៍ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅមណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង។
  - ◦ កម្មវិធីផ្សព្វផ្សាយស្តីពី "ក្រមសីលធម៌មន្ត្រី នៅមណ្ឌលចត្តាឡីស័ក និងសេវាគាំទ្រ" តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាព លោកជំទាវ អចិន្ត្រៃយ៍គ.ជ.ប.ជ ដោយសហការបច្ចេកទេសពីក្រសួងសុខាភិបាល និងទទួលបានការគាំទ្រពីអង្គការយូនីសេហ្វ។
  - ◦ វគ្គបណ្តុះបណ្តាលស្តីពី ការពិគ្រោះយោបល់តាមបែបដោះស្រាយបញ្ហា តាមប្រព័ន្ធអនឡាញ លើកទី៤ ដែលរៀបចំដោយអង្គការបណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា។
  - ◦ កិច្ចប្រជុំថ្នាក់មន្ត្រីជាន់ខ្ពស់ តាមប្រព័ន្ធអនឡាញ នៅទីស្តីការក្រសួងមហាផ្ទៃ ដើម្បីពិនិត្យឯកសារសម្រាប់កិច្ចប្រជុំលើកទី 15AMMTC ក្រោមអធិបតីភាព ឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉ោ ភក្តិ** អគ្គលេខាធិការ និងជាប្រធានក្រុមការងារ SOMTC ។
  - ◦ បន្តកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន(AMMTC) លើកទី១៥ តាមប្រព័ន្ធអនឡាញ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន និងកិច្ចប្រជុំពិគ្រោះយោបល់ដៃគូសន្ទនា ក្រោមអធិបតីភាព សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
  - ◦ បន្តចូលរួមកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន (AMMTC) លើកទី១៥ តាមប្រព័ន្ធអនឡាញ ស្តីពីឧក្រិដ្ឋកម្មឆ្លងដែន ដែលជាកិច្ចប្រជុំពិគ្រោះយោបល់ដៃគូសន្ទនារួមមានប្រទេសចិន ជប៉ុនកូរ៉េ និង AMMTC ក្រោមអធិបតីភាព ឯកឧត្តម **ងី ចាន់ផល** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ព្រមទាំងពិធីផ្ទេរតំណែងប្រធាន AMMTC និង SOMTC ពីប្រទេសប្រ៊ុយណេ មកប្រទេសកម្ពុជាសម្រាប់ឆ្នាំ២០២២ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយលោកនឹងក្លាយជាប្រធានដឹកនាំកិច្ចប្រជុំសម្រាប់ឆ្នាំ២០២១ ដែលប្រទេសកម្ពុជាត្រូវធ្វើជាម្ចាស់ផ្ទះ។
- លោកស្រីវរសេនីយ៍ត្រី **ថោង សុវត្តី** អនុប្រធានក្រុម បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាមួយរដ្ឋបាលខេត្តសៀមរាប តាមប្រព័ន្ធអនឡនឡាញ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គជ.ប.ជ.។
- លោកឧត្តមសេនីយ៍ត្រី អ៊ិន មាន ប្រធានក្រុម បានចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញស្តីពី ការងារទេសន្តប្រវេសន៍ និងការកសាងប្រព័ន្ធ Database ដែលដឹកនាំដោយលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ ជ.ប.ជ.មានអ្នកចូលរួមពីតំណាងក្រុមការងារ GCM តំណាង UN ប្រធានអង្គការ IOM ដើម្បីត្រៀមរៀបចំកិច្ចប្រជុំ GCM ពិភពលោក។

| | |
|---|---|
| | ▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**<br>- ឯកឧត្តម អគ្គលេខាធិការរង បានចូលរួម៖<br>○ កិច្ចប្រជុំស្តីពី ការពង្រឹងសមត្ថភាពគ្រូបង្គោល ត្រៀមសម្រាប់វគ្គបណ្តុះបណ្តាលមេរៀន ការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាពលោកជំទាវអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។<br>○ កិច្ចប្រជុំពិភាក្សា ស្តីពី ការរៀបចំមេរៀនបណ្តុះបណ្តាលសម្រាប់គ្រូបង្គោល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះពីអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគជ.ប.ជ.អនុប្រធានអចិន្ត្រៃយ៍គ ជ ក្រោមអធិបតីភាពលោកជំទាវ.ប.ជ.។<br>○ ធ្វើជាគ្រូឧទ្ទេសក្នុងវគ្គបណ្តុះបណ្តាលពង្រឹងសមត្ថភាព ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដល់មន្ត្រីនៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។<br>○ កិច្ចប្រជុំវាយតម្លៃក្រុមគ្រូបង្គោល សម្រាប់វគ្គបណ្តុះបណ្តាលស្តីពី ការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្សដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាពលោកជំទាវអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។<br>○ សិក្ខាសាលាថ្នាក់តំបន់ស្តីពី ទស្សនៈយេនឌ័រលើការគ្រប់គ្រងអាវុធ និងការរំសាយសព្វាវុធ ទិដ្ឋភាពពីអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ តាមប្រព័ន្ធអនឡាញ ដោយមានការអញ្ជើញចូលរួមពីសមាជិក សមាជិកា នៃប្រទេសអាស៊ាន អង្គការថ្នាក់តំបន់ និងអន្តរជាតិ សង្គមស៊ីវិល សាកលវិទ្យាល័យនៃអាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍ ព្រមទាំងអ្នកពាក់ព័ន្ធ សរុប២៨រូប។<br>○ កិច្ចប្រជុំពិភាក្សាសម្រេចក្នុងការរៀបចំមេរៀនបណ្តុះបណ្តាលសម្រាប់គ្រូបង្គោល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ក្រោមអធិបតីភាពលោកជំទាវអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ។<br>▪ **ក្រុមជំនួយកិច្ចទេសន្តប្រវេសន៍៖**<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី កម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍ តាមប្រព័ន្ធអនឡាញ ជាមួយអង្គការILO រៀបចំសហការដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រោមអធិបតីភាព ឯកឧត្តម **ហ៊ូ វុឌ្ឍី** រដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។<br>- បានចូលរួមប្រជុំរៀបចំមេរៀនបណ្តុះបណ្តាលសម្រាប់គ្រូបង្គោល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ពីអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ ចំនួន**០២**លើក។ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | - បានចូលរួមកិច្ចប្រជុំពិភាក្សា ត្រៀមរៀបចំផែនការសកម្មភាពសម្រាប់ថវិកា ឆ្នាំ២០២២ រវាងនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស ជាមួយអង្គការតេនៈអ៊ិនធើណេសិនណល តាមប្រព័ន្ធអនឡាញ។<br>- បានចូលរួមកិច្ចប្រជុំពិភាក្សាស្តីពី វឌ្ឍនភាពនៃការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការប្រឈម និងដំណោះស្រាយ ជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ក្រោមអធិបតីភាពលោកជំទាវកិត្តិបណ្ឌិត **អ៊ឹង កន្ថាផាវី** រដ្ឋមន្ត្រីក្រសួងកិច្ចការនារី នៅសាលប្រជុំក្រសួងយុត្តិធម៌។ |

| | |
|---|---|
| | - បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ទេសន្តរប្រវេសន៍ដោយសុវត្ថិភាព និងទាក់ទងការដោះស្រាយករណីរួមគ្នា នៅខេត្តសៀមរាប ០១លើក។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ជាមួយអង្គការដំណក់ទឹក តាមប្រព័ន្ធអនឡាញ ០១លើក។<br>- បានចូលរួមកិច្ចប្រជុំស្តីពីការពង្រឹងការភ្ជាប់ទំនាក់ទំនងបណ្តាញសមាជិកក្រុមការងារសិទ្ធិកុមារ ដើម្បីធ្វើបច្ចុប្បន្នភាពលទ្ធផល និងការគាំទ្រសមត្ថភាពពលករចំណាកស្រុក នៅខេត្តសៀមរាប ០១លើក។<br>- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើកទី៣ ស្តីពីការពង្រឹងសេវាសម្របសម្រួលដើម្បីសុវត្ថិភាពពលករ និងសហគមន៍ នៅខេត្តបន្ទាយមានជ័យ ០១លើក។<br>- លោកស្រី **ឈា ម៉ានិត** ប្រធានមជ្ឈមណ្ឌលសំចតប៉ោយប៉ែត បានចូលរួមកិច្ចប្រជុំត្រៀមរៀបចំកិច្ចប្រជុំជាមួយភាគីថៃ ស្តីពីការត្រួតពិនិត្យ ពិភាក្សាលើទម្រង់គ្រប់គ្រងករណី និងឧបសម្ព័ន្ធការអនុវត្តនីតិវិធីប្រតិបត្តិបទដ្ឋាន ០១លើក តាមប្រព័ន្ធអនឡាញ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន ៤២លើក អ្នកចូលរួមសរុបចំនួន ៨១៥នាក់ (ស្រី ១៨៧នាក់)** | |
| **ខេត្តកណ្តាល** | - លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែកញ្ញា ត្រីមាសទី៣ និងលើកទិសដៅអនុវត្តបន្តឆ្នាំ២០២១ ចំនួន០១លើក អ្នកចូលរួមចំនួន **៣៩**នាក់ ស្រី**២២**នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានប្រជុំប្រចាំខែសីហា ចំនួន០៣លើក អ្នកចូលរួមចំនួន **៧៩**នាក់ ស្រី**៤៣**នាក់។<br>- លោកជំទាវ **ហ៊ិន កុសនី** អភិបាលរងខេត្ត បានចូលរួមក្នុងសិក្ខាសាលា ស្តីពីការអនុវត្តគាំពារ និងអភិវឌ្ឍកុមារតូចនៅថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ (Zoom Meeting) ក្រោមអធិបតីភាព លោកជំទាវ **គឹម សេដ្ឋានី** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា។<br>- និងបានចូលរួមប្រជុំក្នុងពិធីប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ " ផែនការអនុវត្តគោលនយោបាយស្តីពីប្រព័ន្ធកិច្ចការពារកុមារ ឆ្នាំ២០១៩-២០២៩ " តាមប្រព័ន្ធអនឡាញ ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច។ |
| **ខេត្តបាត់ដំបង** | - បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើកទី២ តាមប្រព័ន្ធអនឡាញ ដែលរៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីផែនការយុទ្ធសាស្ត្រ ពីសេវាសង្គមនៅកម្ពុជា២០២២-២០២៣ ០១លើក។<br>- បានទទួលជួបសម្ភាសជាមួយអង្គការ Winrock តាមប្រព័ន្ធអនឡាញ ដើម្បីផ្តល់ធាតុចូលវាយតម្លៃពាក់កណ្តាលអាណត្តិ ផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ របស់អង្គការ លើគម្រោងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សនៅកម្ពុជា ០១លើក។<br>- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើកទី៣ ស្តីពីការពង្រឹងសេវាសមស្របដើម្បីសុវត្ថិភាពពលករ និងសហគមន៍នៅមណ្ឌលទទួលពលករកំរៀង ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ។<br>- បានចូលរួមសិក្ខាសាលាស្តីពី ការអនុវត្តការងារការពារ និងអភិវឌ្ឍន៍កុមារតូចនៅថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ ០១លើក។ |

| | |
|---|---|
| | - បាននាំយកអំណោយជាជំនួយរបស់អង្គការILO ជូនពលករដែលបានជាសះស្បើយពីជំងឺកូវីដ-១៩ ចំនួន ២០នាក់ នៅស្រុកសំពៅលូន និងពលករចំនួន ៤០០ នាក់ ដែលកំពុងធ្វើចត្តាឡីស័កនៅស្រុកភ្នំព្រឹក។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី កម្មវិធីសិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍ តាមប្រព័ន្ធអនឡាញ ដែលរៀបចំដោយក្រសួងការងារ។<br>- បានចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ជាមួយអង្គការអន្តរជាតិទេសន្តរប្រវេសន៍ ដើម្បីពិភាក្សា និងបង្ហាញផែនការឆ្លើយតបចំពោះជំងឺកូវីដ-១៩ សម្រាប់ជនទេសន្តរប្រវេសន៍ និងប្រជាជនចល័ត។ |
| ខេត្តសៀមរាប | - បានរៀបចំកិច្ចប្រជុំប្រចាំខែកញ្ញា និងត្រីមាសទី៣ ឆ្នាំ២០២១ ចំនួន០១លើក អ្នកចូលរួម ៨៤នាក់ ស្រី៤០នាក់។<br>- បានជួបពិភាក្សាការងារជាមួយតំណាងអង្គការជំហានដំបូងកម្ពុជា ស្តីពីការចូលរួមទប់ស្កាត់ជំងឺកូវីដ១៩ ក្នុងដំណើរការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។<br>- បានចូលរួមផ្តល់បទសម្ភាសន៍ការប្រមូលធាតុចូលសម្រាប់វាយតម្លៃពាក់កណ្តាលអាណត្តិ នៃផែនការសកម្មភាពជាតិ៥ឆ្នាំ(២០១៩-២០២៣) ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយអង្គការវីនរ៉ក់ តាមប្រព័ន្ធអនឡាញ ០១លើក។<br>- បានចូលរួមកិច្ចប្រជុំជាមួយក្រុមការងារអេធិការកិច្ចចម្រុះហត្ថពលកម្មជនបរទេសស្តីពី ការពិនិត្យលើការប្រើប្រាស់កម្លាំងពលកម្មជនបរទេសក្នុងខេត្តសៀមរាប តាមប្រព័ន្ធអនឡាញ ០១លើក។<br>- បានចូលរួមសម្របសម្រួលទទួល និងបញ្ជូលពលករមកពីខេត្តជាប់ព្រំដែន និងទៅតាមបណ្តារាជធានី ខេត្តនានាជាប្រចាំ។<br>- បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់លើកទី៣ ស្តីពីការបង្កើនសេវាសម្របសម្រួលដើម្បីសុវត្ថិភាពពលករ និងសហគមន៍ ក្រោមអធិបតីលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅសាលាខេត្តសៀមរាប។ |
| ខេត្តកំពង់ឆ្នាំង | - បានរៀបចំកិច្ចប្រជុំប្រចាំខែកញ្ញា ០១លើក និងកិច្ចប្រជុំគណកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារថ្នាក់ស្រុក ០១លើក អ្នកចូលរួម១៦នាក់ ស្រី១៥នាក់។<br>- កិច្ចប្រជុំប្រមូលធាតុចូលសម្រាប់វាយតម្លៃពាក់កណ្តាលអាណត្តិ ផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ(២០១៩-២០២៣) ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់លេខាធិការដ្ឋានគ.ខ.ប.ជ ខេត្ត តាមប្រព័ន្ធអនឡាញ ០១លើក។<br>- បានចូលរួមផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំគ.ក.ស.ក ស្តីពីការធ្វើចំណាកស្រុក ចំនួន០២លើក អ្នកចូលរួម ៥០នាក់ ស្រី៣៤នាក់។ |
| ខេត្តកំពង់ចាម | - បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ ផែនការយុទ្ធសាស្ត្រជាតិ៥ឆ្នាំ(២០១៩-២០២៣) ពាក់ព័ន្ធនឹងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ តាមប្រព័ន្ធអនឡាញ។<br>- បានចូលរួមសិក្ខាសាលាថ្នាក់ជាតិស្តីពី ពលករទេសន្តរប្រវេសន៍ ០១លើក តាមប្រព័ន្ធអនឡាញ មានអ្នកចូលរួមប្រមាណ ៦១នាក់។<br>- បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិស្តីពី សិទ្ធិពលករនេសាទនៅអាស៊ីអាគ្នេយ៍ ០១លើក រៀបចំដោយអង្គការពលកម្មអន្តរជាតិ(ILO)។ |

| | |
|---|---|
| | - បានចូលរួមសិក្ខាសាលាតាមប្រព័ន្ធអនឡាញ ស្តីពីការជួញដូរមនុស្ស ការងារដោយបង្ខំ និងទាសភាពក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក រៀបចំដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ នៃប្រទេសកូរ៉េខាងត្បូង។<br>- បានចូលរួមប្រជុំពិភាក្សាអំពីការអនុវត្តការងាររបស់គ.ខ.ប.ជ តាមប្រព័ន្ធអនឡាញ ក្រោមកិច្ចសហការជាមួយអង្គការជំនួយផ្លូវច្បាប់ដល់កុមារ និងស្ត្រី។ |
| ខេត្តកំពង់ធំ | - លោកជំទាវប្រធានលេខាធិការដ្ឋានគ.ខ.ប.ជ និងសមាជិក បានចូលរួមទទួលពលករដែលវិលត្រឡប់មកពីប្រទេសថៃ ០១លើក និងត្រូវដាក់ឱ្យធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ ដើម្បីការពារការឆ្លងរីករាលដាល នៃជំងឺកូវីដ១៩ ។<br>- លោកស្រីស្នងការរងនគរបាលខេត្ត បានចូលរួមប្រជុំសាមញ្ញប្រចាំខែសីហា ឆ្នាំ២០២១ របស់គណៈកម្មាការពិគ្រោះយោបល់ស្ត្រី និងកុមារខេត្ត តាមប្រព័ន្ធអនឡាញ ០១លើក។ |
| ខេត្តឧត្តរមានជ័យ | - បានប្រជុំគណៈកម្មាធិការពិគ្រោះយោបល់លើកិច្ចការស្ត្រី និងកុមារ ចំនួន០១លើក អ្នកចូលរួមចំនួន១៨នាក់ ស្រី០៣នាក់។ |
| ខេត្តព្រៃវែង | - លោកជំទាវ អភិបាលរង និងជាប្រធានលេខាធិកាដ្ឋានគ.ខ.ប.ជ បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ដើម្បីផ្តល់ធាតុចូលលើមាតិកា នៃសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារកុមារកម្ពុជា តាមប្រព័ន្ធអនឡាញ ០១លើក។<br>- បានចូលរួមសិក្ខាសាលាស្តីពីការអនុវត្តការងារគាំពារ និងអភិវឌ្ឍន៍កុមារតូចនៅថ្នាក់ក្រោមជាតិ តាមប្រព័ន្ធអនឡាញ ០១លើក។<br>- បានចូលរួមជាអធិបតីក្នុងពិធីប្រកាសដាក់ឱ្យប្រើប្រាស់ជាផ្លូវការផែនការអនុវត្តគោលនយោបាយជាតិស្តីពី ប្រព័ន្ធការពារកុមារ ក្រោមអធិបតីភាព លោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច តាមប្រព័ន្ធអនឡាញ ០១លើក។ |
| ខេត្តបន្ទាយមានជ័យ | - បើកកិច្ចប្រជុំពិគ្រោះយោបល់លើកទី៣ ស្តីពីការបង្កើនសេវាសម្របសម្រួលដើម្បីសុវត្ថិភាពពលករ និងសហគមន៍ក្នុងអំឡុងពេលនៃការរីករាលដាលជំងឺកូវីដ-១៩ ចំនួន ០១លើក។<br>- បើកកិច្ចប្រជុំត្រួតពិនិត្យ និងដាក់ផែនការពង្រឹងការត្រួតពិនិត្យសន្តិសុខ បទល្មើស និងការទប់ស្កាត់ពលករឆ្លងដែនតាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ ០១លើក។ |
| ខេត្តក្រចេះ | - មន្ទីរអប់រំ យុវជន និងកីឡា បាន៖ ១.ចូលរួមប្រជុំផ្សព្វផ្សាយនៅសាលាគរុកោសល្យ និងវិក្រិតការខេត្ត តាមប្រព័ន្ធអនឡាញ ស្តីពីការរំលោភបំពានគ្រប់រូបភាពលើកុមារ ពិសេសកុមារី និងកុមារត្រូវបានគេជួញដូរពលកម្មនៅតាមមូលដ្ឋាន អ្នកចូលរួម ៤៨នាក់ ស្រី៣០នាក់។ ២.រៀបចំអោយមានគណៈកម្មាការទប់ស្កាត់ការជួញដូរមនុស្ស ពីថ្នាក់មន្ទីរអប់រំ រហូតដល់ថ្នាក់ស្រុក និងសាលារៀន។<br>- មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍៖ ១.បានចូលរួមសិក្ខាសាលា ស្តីពីកិច្ចការពារកុមារលើប្រព័ន្ធអនឡាញនៅកម្ពុជា រៀបចំដោយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា តាមប្រព័ន្ធZOOM។ ២.រៀបចំកិច្ចប្រជុំប្រចាំខែ និងបានបញ្ជ្រាបខ្លឹមសារការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការរំលោភផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមប្រព័ន្ធអនឡាញ។ |

| | |
|---|---|
| **ខេត្តព្រះវិហារ** | - បានចូលរួមកិច្ចប្រជុំ តាមប្រព័ន្ធអនឡាញ ជាមួយគ.ជ.ប.ជ ស្តីពីផលប៉ះពាល់ជំងឺកូវីដ-១៩ លើសុខភាពផ្លូវចិត្ត ការពង្រឹងផ្លូវចិត្ត និងស្តីពីអំពើជួញដូរមនុស្ស ការរំលោភបំពាន សម្រាប់បុគ្គលស្ថិតក្នុងមណ្ឌលចត្តាឡីស័ក ០១លើក។ |
| **ខេត្តប៉ៃលិន** | - លោកស្រី **ឡូញ ឈាង** អភិបាលរង នៃគណៈអភិបាលខេត្ត អមដំណើរដោយលោក **ស្រេង វិច្ឆិកា** នាយករងទីចាត់ការអន្តរវិស័យ បានចូលរួមកិច្ចប្រជុំ ពិគ្រោះយោបល់លើកទី៣ ស្តីពីកិច្ចប្រជុំការពង្រឹងសេវាសម្របសម្រួល ដើម្បីសុវត្ថិភាពពលករ និងសហគមន៍ ក្រោមអធិបតីភាពលោកជំទាវ អនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ នៅមណ្ឌលទទួលពលករកំរៀង ខេត្តបាត់ដំបង។ |